# សេចក្តីថ្លែងការណ៍

## អបអរសាទរទិវាអ្នកចំណាកស្រុកអន្តរជាតិ ១៨ ធ្នូ លើកទី២៦

**"លើកកម្ពស់សុវត្ថិភាព ការងារសមរម្យ និងប្រព័ន្ធជំនួយសង្គមដល់ពលករចំណា**កស្រុក"

ដោយទទួលបានការគាំទ្រដោយ អង្គការអន្តរជាតិខាងការងារ (ហៅកាត់ថា ILO) គម្រោងពលករទូកនេសាទប្រចាំតំបន់អាស៊ីអាគ្នេយ៍ និង អង្គការ IOM ប្រចាំប្រទេសកម្ពុជា អង្គការសង់ត្រាល់(CENTRAL)រួមជាមួយក្រុមអ្នកស្ម័គ្រចិត្តប្រឹក្សាយោបល់សុវត្ថិភាព (ស្មា-SMAs) សហការជាមួយ អាជ្ញាធរមូលដ្ឋាន រួមគ្នារៀបចំ ទិវាអ្នកចំណាកស្រុកអន្តរជាតិ ខួបលើកទី២៦ ក្រោមប្រធានបទ **«លើកកម្ពស់សុវត្ថិភាព ការងារសមរម្យ និងជំនួយសង្គម ដល់ពលករចំណាកស្រុក»** នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ នៅតាមវត្តអារាម សហគមន៍ ជំរំភៀសសឹក ស្ថិតក្នុងភូមិ ឃុំ ស្រុក ខេត្តមួយចំនួន ដែលមានអតីតពលករ កម្មករ ពលរដ្ឋ យុវជន និងគ្រួសារពលករ បានភៀសសឹកសុវត្ថិភាព ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពីសុវត្ថិភាព រួមចំណែកការពារហានីភ័យ បង្ការ ការពារ ទប់ស្កាត់ ការចំណាកស្រុកទាំងប្រថុយប្រថាន អំឡុងពេលជម្លោះតាមព្រំដែន។

ឆ្លៀតក្នុងឱកាស អបអរទិវាអ្នកចំណាកស្រុកអន្តរជាតិនេះ អង្គការសង់ត្រាល់ (CENTRAL) បានបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីអំពីស្ថានភាពសេដ្ឋកិច្ចរបស់ពលករខ្មែរ ដែលបានត្រឡប់មកវិញនិងការគាំទ្រដែលពួកគេត្រូវការបន្ទាន់។ របាយការណ៍បង្ហាញ ពីស្ថានភាពសម្ពាធផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរ ដែលពលករទាំងនេះ កំពុងប្រឈម និងសេចក្តីត្រូវការរបស់ពួកគេ។

**លោក មឿន តុលា** នាយកប្រត្តិបត្តិអង្គការ (CENTRAL) បានលើកឡើងថា *«ពលករជាច្រើនបានត្រឡប់មកវិញដោយត្រូវចំណាយថវិកាផ្ទាល់ខ្លួន ហើយទទួល បាន ជំនួយតិចតួច ខណៈដែលបំណុលនៅតែជាហេតុផលចម្បង ក្នុងការសម្រេច ចិត្តចំណាកស្រុកជាថ្មីម្តងទៀត។ អ្នកឆ្លើយតបបានស្នើសុំឲ្យមានការងារ ដែលមាន គុណភាពសមរម្យ ការពន្យារពេលបង់បំណុល ជាបណ្តោះអាសន្ន ការគាំទ្រផ្នែកអាហារ និងការទទួលបានសេវាកិច្ចគាំពារផ្នែកសង្គម ដើម្បីគាំទ្រដំណើរការណ៍ ការធ្វើសមាហរណកម្មប្រកបដោយសុវត្ថិភាព»។*

**លទ្ធផលសង្ខេបនៃការការសិក្សាស្រាវជ្រាវស្តីពីផលប៉ះពាល់បានបង្ហាញថា៖**

- *មានតែ ៣១% ប៉ុណ្ណោះទទួលបានជំនួយ ការជួយសង្គ្រោះបឋម ដែលភាគច្រើនមកពីរដ្ឋាភិបាលកម្ពុជា។*
- *ការចំណាយជាមធ្យមអំឡុងពេលវិលត្រឡប់មកវិញ៖ ៧៤ ដុល្លារ ចំណាយលើការដឹកជញ្ជូន: ១៤៥ ដុល្លាចំណាយលើអាហារ ៥៦ ដុល្លារ ចំណាយលើការបង់ប្រាក់ក្រៅប្រព័ន្ធ:*
- *៧១% នៃពលករវិលត្រលប់មកវិញ មានជាប់បំណុល ក្នុងនោះមាន៨៥% មិនអាចបង់តាមកាលកំណត់បាន។ បំណុលជាមធ្យមមានចន្លោះពី ៣០.៨០ ដុល្លារ – ៣៥,០០០ ដុល្លារ (ជាមធ្យម ៥,៥០០ ដុល្លារ)។ ការបង់សងប្រចាំខែជាមធ្យម: ២២០ ដុល្លារ។*
- *៥៣% មានគម្រោងចំណាកស្រុកជាថ្មីម្តងទៀត; ក្នុងនោះ ៧៨% ចង់ត្រឡប់ទៅប្រទេសថៃ*

**អ្វីខ្លះដែលពលករចូលរួមសម្ភាសន៍អំពាវនាវស្នើសុំ?**

- *ការងារដែលមានស្ថិរភាព និងមានគុណភាពសមរម្យ, រួមទាំងឱកាសសម្រាប់អ្នកមានអាយុលើសពី ៤០ ឆ្នាំ ឡើងទៅ។*
- *មូលនិធិហិរញ្ញវត្ថុ ចាប់ផ្តើមពីអាជីវកម្មខ្នាតតូច។*
- *បង្កើនតម្លៃនៃការបញ្ជាទិញ ស្រូវអង្ករ និង ធានាឱ្យមានការប្រគួតប្រជែងលើទីផ្សារដោយយុត្តិធម៌ ដើម្បីគាំទ្រសហគ្រិនកសិកម្មក្នុងស្រុក។*
- *យ៉ាងហោចណាស់ ផ្អាកការបង់បំណុលយ៉ាងតិច ៦ ខែ។*
- *ពង្រីកវិសាលភាពគ្របដណ្តប់ ប.ស.ស បណ្តុក្រីក្រ និង ជំនួយផ្នែកអាហារអំឡុងពេលធ្វើសមាហរណកម្ម។*

ក្នុងឱកាសអបអរសាទរទិវាអ្នកចំណាកស្រុកអន្តរជាតិនេះ អង្គការសង់ត្រាល់ (CENTRAL) អំពាវនាវឲ្យមានការពង្រឹងកិច្ចសហប្រត្តិបត្តិការល្អដោយប្រើប្រាស់របកគំហើញទាំងអស់នេះ ដើម្បីគាំទ្រពលករចំណាកស្រុក ដែលបានវិលត្រលប់មកវិញ ក្នុងអំឡុងពេលដែលមានតម្រូវការបន្ទាន់នេះ។ សម្រាប់របាយការណ៍ពេញលេញចុងក្រោយ និងត្រូវចេញផ្សាយក្នុងពេលឆាប់ៗ ខាងមុខនេះ។

- សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖ ***លោក ឌី ថេហ្សយ៉ា*** ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់
- ទូរស័ព្ទ៖ 093 55 66 31